គណៈកម្មាធិការដើម្បីសិទ្ធិបោះឆ្នោតរបស់ពលរដ្ឋខ្មែរនៅក្រៅប្រទេស
**COMMITTEE FOR ELECTION RIGHTS OF OVERSEAS CAMBODIANS (THE CEROC)**
**Email:** board@khmeroversea.info, www.khmeroversea.info

# សម្តេចក្រឡាហោមស ខេង

## ប្រធានក្រុមតំណាងរាស្ត្រមតិភាគច្រើនក្នុងរដ្ឋសភា គណបក្សប្រជាជនកម្ពុជា

**<u>សំណូមពរៈ</u>** ធ្វើវិសោធនកម្មច្បាប់ដើម្បីធានាសិទ្ធិបោះឆ្នោតរបស់ពលរដ្ឋខ្មែរនៅក្រៅប្រទេស

គណៈកម្មាធិការដើម្បីសិទ្ធិបោះឆ្នោតរបស់ពលរដ្ឋខ្មែរនៅក្រៅប្រទេសហៅកាត់ថាស៊ីរ៉ក់ កត់សំគាល់ឃើញថាការរៀបចំការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់កន្លងមកថ្មីៗនេះ គណៈកម្មការរៀបចំការបោះឆ្នោតជាតិបានបំពេញការងាររបស់ខ្លួនល្អប្រសើរជាងមុនដោយសំរិតសំរាំងបញ្ជីឈ្មោះអ្នកបោះឆ្នោត និងនីតិវិធីប្រកាស់លទ្ធផលឆ្នោតតាមរយៈបណ្តាញអិនតើណិតដោយចំឡងសំណៅដើមទាំងស្រុងពីការិយាល័យរាប់សន្លឹកឆ្នោតនិមួយៗទូទាំងប្រទេស។ ទន្ទឹមនឹងភាពល្អប្រសើរនេះ ក៍មានចំណុចដែលត្រូវកែតម្រូវអោយប្រសើរឡើងដែរដូចជាសមធម៍ក្នុងការប្រើប្រាស់ថវិកាឃោសនា ឯករាជ្យភាពពិតប្រាកដរបស់អង្គភាពគ.ជ.ប.ដោយមិនគួរស្ថិតក្រោមយុត្តាធិការរបស់ក្រសួងណាមួយឡើយ និងការផ្តល់សិទ្ធិបោះឆ្នោតពេញលេញដល់ពលរដ្ឋខ្មែរនៅក្រៅប្រទេសទាំងអស់ជាពិសេសពលករចំណាកស្រុកនិងពលរដ្ឋខ្មែរដែលកំពុងរស់នៅប្រទេសទីបីនៅជុំវិញពិភពលោក។

ប្រជាពលរដ្ឋខ្មែរនៅក្រៅប្រទេសបានទទួលសិទ្ធិបោះឆ្នោតពេញលេញក្នុងកំឡុងការរៀបចំបោះឆ្នោតដែលរៀបចំឡើងដោយអង្គការសហប្រជាជាតិឬដែលហៅកាត់ថាអ៊ុនតាក់នៅឆ្នាំ១៩៩៣។ តែក្រោយមក គ.ជ.ប.មិនបានយកច្បាប់បោះឆ្នោតអ៊ុនតាក់មកប្រើប្រាស់ ហើយរមែងព្រងើយកន្តើយសិទ្ធិចូលរួមនយោបាយរបស់ពលរដ្ឋខ្មែរនៅក្រៅប្រទេសតាមរយៈការចូលរួមបោះឆ្នោតជ្រើសរើសតំណាងរបស់ខ្លួនដែលសិទ្ធិនេះត្រូវបានធានាដោយច្បាប់រដ្ឋធម្មនុញ្ញជាតិតាមមាត្រា៣៤និងច្បាប់ស្តីអំពីសិទ្ធិមនុស្សជាសាកលរបស់អង្គការសហប្រជាជាតិតាមមាត្រា២១។

ដូច្នេះសូមសម្តេចមេត្តាពិចារណានិងដាក់វារៈនេះជាអាទិភាពក្នុងរដ្ឋសភាជាតិ។

សូមសម្តេចទទួលបាននូវពុទ្ធពរទាំងឡាយ៤ប្រការកុំបីឃ្លៀងឃ្លាតឡើយ។

ធ្វើនៅប្រទេសកាណាដា ថ្ងៃទី៤ កក្កដា ២០១៧

**សេង សុភ័ណ**

ប្រធានគណៈកម្មាធិការដើម្បីសិទ្ធិបោះឆ្នោតរបស់ពលរដ្ឋខ្មែរនៅក្រៅប្រទេស

Committee for Election Rights of Overseas Cambodians (The CEROC)
Contact: 6596 Marlborough Ave., Burnaby, BC, V5H 3M1, Canada
Tel: 604-428-4385, Fax: 604-620-3433